## ព្រះរាជាណាចក្រកម្ពុជា

### ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តបាត់ដំបង**

សំណុំរឿងព្រហ្មទណ្ឌលេខៈ១៥២៩

ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១

**សាលក្រមលេខ: ៥៩៥ "ខ"**

ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តបាត់ដំបង

បានបើកសវនាការជាសាធារណៈនាថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២២ និងប្រកាសសាលក្រមនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ ដោយមានសមាសភាពៈ

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមប្រឹក្សា

លោកស្រី [redacted] ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជី

ដើម្បីជំនុំជម្រះលើជនជាប់ចោទឈ្មោះ [redacted] ចែម ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិ [redacted] ទីលំនៅសព្វ [redacted] ឳពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) នៅលីវ ទោសពីមុនធ្លាប់ជាប់ពន្ធនាគាររយៈពេល ៣ឆ្នាំ (*ឃុំខ្លួនថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១*)។

ពីបទៈ **ជួញដូរ** និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចក្រុមទី៣ ភូមិតាគុក២ ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០២១ និងថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ដោយមានលោក [redacted] សុខា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ មានការិយាល័យផ្ទះលេខ ១៥១ ផ្លូវលេខ ១០៤A ក្រុមទី៤ ភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។

### អង្គហេតុមានដូចតទៅ

កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ នៅចំណុចក្រុមទី១ ភូមិតាគុក២ ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង កម្លាំងសមត្ថកិច្ចបានធ្វើការបង្ក្រាបករណីគ្រឿងញៀន ដែលបង្កឡើងដោយជនសង្ស័យឈ្មោះ [redacted] ចែម ភេទប្រុស អាយុ ៣០ឆ្នាំ និងបក្សពួកម្នាក់ទៀត បានប្រើប្រាស់ទូរស័ព្ទលេខ ០៩៧ ២២២ ៤៤៩៩

ស្កេនជាមួយ CamScanner

បានទិញគ្រឿងញៀនពីឈ្មោះ ធី ភេទប្រុស រស់នៅខេត្តពោធិ៍សាត់ យកមករក្សាទុកក្នុងម៉ូតូ។ ក្រោយពីជនសង្ស័យបានចេញពីច្រៀងខារ៉ាអូខេវិញ ក៏ត្រូវសមត្ថកិច្ចឆែកឆេរឃើញគ្រឿងញៀននៅក្នុងម៉ូតូចំនួន ០៣កញ្ចប់ ទម្ងន់ចំនួន ៥៧,២៣ក្រាម និងបានឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] ថែម យកមកសាកសួរតែម្តង ចំណែកឯជនមិនស្គាល់ឈ្មោះម្នាក់ទៀតបានរត់គេចខ្លួនបាត់។ ក្រោយពីធ្វើការសាកសួរជនសង្ស័យបានសារភាពថា នៅអំឡុងខែវិច្ឆិកា ឆ្នាំ២០២១ ខ្លួនធ្លាប់រត់ការទិញគ្រឿងញៀនឲ្យអ្នកផ្សេងបានជាច្រើនលើកច្រើនសារ ដោយក្នុង០១លើកបានប្រាក់ចំនួន ៥០.០០០រៀល ទៅ១០០.០០០រៀល។

-បានឃើញដីកាដំណោះស្រាយលេខៈ ២៨៤ ដជរ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបង ។

-បានឃើញដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខៈ ២២០៧ ត.ព្រ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តបាត់ដំបង។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ថែម បានឆ្លើយថាៈ ថ្ងៃកើតហេតុខ្លួនបានទៅច្រៀងខារ៉ាអូខេជាមួយពួកជាងសំណង់ដែលធ្វើផ្ទះឲ្យបងប្អូនរបស់ខ្លួនដែលនៅទល់មុខផ្ទះរបស់ខ្លួន លុះក្រោយពេលពួកជាងសំណង់ចេញពីកន្លែងច្រៀងខារ៉ាអូខេវិញ ស្រាប់តែសមត្ថកិច្ចបានមកដល់ និងតាមចាប់ពួកគាត់។ ដោយពេលនោះខ្លួនបាននៅក្បែរនោះដែរទើបសមត្ថកិច្ចសួរខ្លួនថាមកច្រៀងជាមួយពួកគេដែរឬអត់ ហើយសមត្ថកិច្ចបានឲ្យខ្លួននៅរង់ចាំនៅទីនោះសិន បន្ទាប់មកសមត្ថកិច្ចបានឆែកឆេរលើរូបខ្លួន និងម៉ូតូរបស់ខ្លួនដើម្បីរកគ្រឿងញៀន ប៉ុន្តែពេលនោះឆែកពុំឃើញគ្រឿងញៀនទេ ហើយសមត្ថកិច្ចក៏បាននាំខ្លួនទៅប៉ុស្តិ៍។ ពេលទៅដល់ប៉ុស្តិ៍សមត្ថកិច្ចបានយកម៉ូតូរបស់ខ្លួនចេញទៅក្រៅប្រហែលរយៈពេល ១ម៉ោងទើបត្រឡប់មកវិញ ហើយបានប្រាប់ខ្លួនថាឃើញមានគ្រឿងញៀននៅក្នុងម៉ូតូរបស់ខ្លួន។ សូមបញ្ជាក់ថាគ្រឿងញៀនទាំងនោះពុំមែនជារបស់ខ្លួនទេ ហើយនៅពេលដែលសមត្ថកិច្ចឆែករកគ្រឿងញៀននៅកន្លែងច្រៀងខារ៉ាអូខេនោះគឺពុំឃើញមានគ្រឿងញៀននៅម៉ូតូរបស់ខ្លួនទេ ឲ ហើយនៅកន្លែងឆែកឆេរនោះមានកាំមេរ៉ាសុវត្ថិភាព ហើយកាំមេរ៉ានេះសមត្ថកិច្ចបានដកហូតយកទៅរក្សាទុក។ នៅថ្ងៃកើតហេតុខ្លួនពុំបានប្រព្រឹត្តអំពើរក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដូចការចោទប្រកាន់នោះទេ។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

គ្រឿងញៀនដែលដកហូតបានមានចំនួនច្រើន ហើយកន្លែងកើតហេតុមានកាមេរ៉ាសុវត្ថិភាព ហើយជនជាប់ចោទបានឆ្លើយបដិសេធថាគ្រឿងញៀនទាំងនោះពុំមែនជារបស់ខ្លួនទេ។ ចំណុចនេះសុំអោយតុលាការពិចារណាថាតើត្រូវបើក ឬមិនចាំបាច់បើកមើលកាំមេរ៉ាសុវត្ថិភាពរបស់ម្ចាស់ហាងខារ៉ាអូខេ។ ប៉ុន្តែក្នុងរឿងនេះតំណាងអយ្យការនៅតែតំកល់ការចោទប្រកាន់ដដែល និងស្នើសុំឲ្យតុលាការពិចារណាតាមភស្តុតាងជាក់ស្តែង។



ស្កេនជាមួយ CamScanner

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

ទាក់ទងនឹងសំណុំរឿងនេះ ដោយកូនក្តីរបស់ខ្លួនត្រូវជាប់ពីបទគ្រឿងញៀនមានចំនួនច្រើន។ ចម្លើយកូនក្តីរបស់ខ្លួនគឺនៅដដែល ដោយហេតុថាគ្រឿងញៀនទាំងនោះពុំមែនជារបស់កូនក្តីខ្លួនទេ។ ចម្លើយនៅសមត្ថកិច្ចមានការប្រើហិង្សាយកចម្លើយ។ ចំពោះកាមេរ៉ាសុវត្ថិភាពគឺសមត្ថកិច្ចដកហូតឡើងពុំទាន់ឲ្យម្ចាស់ហាងទេ ហើយសាក្សីផ្សេងៗពុំបានមកបំភ្លឺទេ។ ក្នុងរឿងនេះពុំមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទដូចការចោទប្រកាន់នោះទេ ដូច្នេះស្នើសុំឲ្យតុលាការសម្រេចឲ្យជនជាប់ចោទរួចផុតពីបទចោទ។

ជនជាប់ចោទឈ្មោះ [redacted] ចែម បានឆ្លើយថាខ្លួនមានសំណូមពរសុំឲ្យតុលាការលើកលែងការចោទប្រកាន់។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

ក្រោយពីបានស្តាប់សំណូមពរជាសម្តីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការខេត្តបាត់ដំបង**

**យល់ឃើញថា**

១-តាមដីកាដំណោះស្រាយលេខ ២៨៤ ដជរ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបង ឃើញថាជនជាប់ចោទឈ្មោះ [redacted] ចែម ភេទប្រុស អាយុ ៣០ឆ្នាំ បានបញ្ជូនមកជំនុំជម្រះពីបទ ជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចក្រុមទី៣ ភូមិតាគុក២ ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០២១ និងថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ និងអំឡុងខែវិច្ឆិកា ឆ្នាំ២០២១ នៅចំណុចភូមិតាគុក២ ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង ពិតជាមានអំពើជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀនបានកើតឡើងពិតប្រាកដមែន ដែលបង្កដោយជនជាប់ចោទឈ្មោះ [redacted] ចែម ភេទប្រុស អាយុ ៣០ឆ្នាំ បានទិញគ្រឿងញៀនចំនួន ០៣កញ្ចប់ ទម្ងន់ ៥៧,២៣ក្រាម ពីឈ្មោះ ធី ភេទប្រុស រស់នៅខេត្តពោធិ៍សាត់យកមករក្សាទុកក្នុងម៉ូតូ និងលក់ចែកចាយបន្ត។ អំពើនេះជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-ចម្លើយរបស់ជនជាប់ចោទនាពេលសវនាការដែលបានឆ្លើយបដិសេធថា នៅថ្ងៃកើតហេតុខ្លួនពុំបានប្រព្រឹត្តអំពើរក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដូចការចោទប្រកាន់នោះ គឺគ្រាន់តែជាការឆ្លើយដោះសារដើម្បីបានរួចផុតពីការទទួលខុសត្រូវតែប៉ុណ្ណោះ ដោយតុលាការពុំអាចជឿបានឡើយពីព្រោះថានៅថ្ងៃកើតហេតុនោះ សមត្ថកិច្ចបានឆែកឆេរឃើញគ្រឿងញៀនដាក់ស្តែងនៅក្នុងម៉ូតូរបស់ជនជាប់



ស្កេនជាមួយ CamScanner

ចោទរូបនេះដែលគ្រឿងញៀននេះជាគ្រឿងញៀន ដែលជនជាប់ចោទលក់ចែកចាយទៅឲ្យអ្នកជំទៃនៅកន្លែងច្រៀងខារ៉ាអូខេ។ ម៉្យាងទៀតជនជាប់ចោទរូបនេះបានឆ្លើយសារភាពនៅដំណាក់កាលសមត្ថកិច្ចថា កន្លងមកខ្លួនធ្លាប់បានទិញគ្រឿងញៀនអោយគេជាច្រើនលើក ដោយទំនាក់ទំនង និងវេលុយអោយគ្នាតាមរយៈលេខ ០៨៧ ៨៤៥៥៥៤ និងអាខោន facebook Bjam Singer ទិញដូរថ្នាំញៀនម្តងៗតម្លៃចាប់ពី ៤០០.០០០រៀល ទៅ ១.០០០.០០០រៀល ហើយចំណេញបានចាប់ពី ៥០.០០០រៀល ទៅ ១០០.០០០រៀល ដោយធ្លាប់ទិញថ្នាំញៀនពីឈ្មោះ ធី។

៤-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការនាពេលសវនាការ បានតំកល់ការចោទប្រកាន់លើជនជាប់ចោទដដែល និងបានស្នើសុំឲ្យតុលាការពិចារណាតាមភស្តុតាងជាក់ស្តែង។

៥-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ ដែលបានស្នើសុំឲ្យតុលាការសម្រេចឲ្យជនជាប់ចោទរួចផុតពីបទចោទនោះ តុលាការនឹងពិចារណាតាមភស្តុតាងជាក់ស្តែង។

៦-តាមលិខិតលេខ ៣៥៧២៥/២២ មពអជបគញ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ របស់មន្ទីរពិសោធន៍នៃអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបញ្ជាក់ថាសំណាកគ្រឿងញៀនជាប្រភេទម្សៅក្រាមពណ៌សថ្លាដែលដកហូតយកទៅធ្វើកោសល្យវិច័យនោះ គឺមានភាពវិជ្ជមាននូវវត្តមានសារធាតុញៀនឈ្មោះមេតំហ្វេតាមីនដែលមានភាគរយសុទ្ធស្មើនឹង ៧៨.៥០%។

៧-ផ្អែកតាមរបាយការណ៍ស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌ លិខិតលេខ ៣៥៧២៥/២២ មពអជបគញ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ របស់មន្ទីរពិសោធន៍នៃអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងភស្តុតាងជាឯកសារមួយចំនួនផ្សេងទៀតនៅក្នុងសំណុំរឿងគឺជាភស្តុតាងជាក់បន្ទុកដែលមានលក្ខណៈគ្រប់គ្រាន់អាចបញ្ជាក់បានថាកាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០២១ និងថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ ជនជាប់ចោទឈ្មោះ [redacted] ចែម ពិតជាបានប្រព្រឹត្តបទល្មើស ជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ដូចការចោទប្រកាន់មែន។

៨-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ចែម ភេទប្រុស អាយុ ៣០ឆ្នាំ ពីបទ ជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចក្រុមទី៣ ភូមិតាកុក២ ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០២១ និងថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៩-ជនជាប់ចោទជានីតិជនមានសមត្ថភាព និងស្មារតីគ្រប់គ្រាន់ក្នុងពេលប្រព្រឹត្តបទល្មើស គប្បីត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

១០-វត្ថុចាប់យកមានម្សៅក្រាមពណ៌សថ្លាជាប្រភេទថ្នាំញៀនមេតំហ្វេតាមីនទម្ងន់ ៥១,៨៩ក្រាម ដូចមាននៅក្នុងកំណត់ហេតុរាប់ថ្លឹង និងដកសំណាកគ្រឿងញៀនចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបង ព្រមទាំងទូរស័ព្ទដៃចំនួន ០១គ្រឿង កាបូបលុយចំនួន ០១ ប្រាក់ចំនួន ២៦,៥០០រៀល ដូចមាននៅក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៦១១វត ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង គប្បីសម្រេចរឹបអូស។

១១- សំណូមពរជាសម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ចែម ដែលបានស្នើសុំអោយតុលាការលើកលែងការចោទប្រកាន់នោះ តុលាការមិនលើកមកពិចារណាឡើយ។



ស្កេនជាមួយ CamScanner

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ផ្តន្ទាទោសលើឈ្មោះ [redacted] ថែម ភេទប្រុស អាយុ ៣០ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៦ (ប្រាំមួយ)ឆ្នាំ និងពិន័យជាប្រាក់ដាក់ចូលថវិការដ្ឋចំនួន ១០,០០០,០០០(ដប់លាន)រៀល ពីបទៈ ជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចក្រុមទី៣ ភូមិតាកុក២ ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០២១ និងថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-វត្ថុចាប់យកមានម្សៅក្រាមពណ៌សថ្លាជាប្រភេទថ្នាំញៀនមេតំហ្វេតាមីនទម្ងន់ ៥១,៨៩ក្រាម ដូចមាននៅក្នុងកំណត់ហេតុរាប់ថ្លឹង និងដកសំណាកគ្រឿងញៀនចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបង ព្រមទាំងទូរស័ព្ទដៃចំនួន ០១គ្រឿង កាបូបលុយចំនួន ០១ ប្រាក់ចំនួន ២៦,៥០០រៀល ដូចមាននៅក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៦១១វត ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង សម្រេចរឹបអូស។

៣-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ថែម។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ក្រឡាបញ្ជីសវនាការ

[redacted]

ចៅក្រមប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



ស្កេនជាមួយ CamScanner